# ស្ទោង/ជីក្រែង/កំពង់ស្វាយ A1 & A3



| | | |
|---|---|---|
| **ខេត្ត** | : | កំពង់ធំ និង សៀមរាប |
| **ស្រុក** | : | ស្ទោង ជីក្រែង និង កំពង់ស្វាយ |
| **ផ្ទៃដី ( ហិកតា)** | : | ៥៣.៥៤៣ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ៤ ដល់ ១៧ |
| **កូអរដោនេចំណុចកណ្ដាល** | : | ១២°៥៧' ជ ១០៤°២៥' ក |

### ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ រួមមានតំបន់វាលស្មៅធំបំផុតនៅក្នុងតំបន់លិចទឹកបឹងទន្លេសាប ។ រុក្ខជាតិនៅក្នុងតំបន់នេះមានលក្ខណៈជាស្មៅទាប ខ្ពស់ ដុះលាយឡំជាមួយព្រៃគុម្ពោតក្រាស់ៗ វាលស្រែ និង តំបន់ដីសើមមាននៅរាយប៉ាយក្នុងតំបន់នេះទាំងមូល ។ នៅរដូវវស្សា គេធ្វើស្រូវនៅតាមជាយតំបន់នេះនៅប៉ែកខាងជើងជាប់នឹងផ្លូវជាតិលេខ៦A ។ តំបន់វាលស្មៅលិចទឹកតាមរដូវកាលបានទ្រទ្រង់ដង់ស៊ីតេនៃចំនួនសត្វខ្សឹបច្រើនជាងគេបំផុតដែលបានរកឃើញកន្លងមកនៅក្នុងប្រទេសកម្ពុជា ។ បឹង និង ត្រពាំងតូចៗទាំងនោះគឺជាតំបន់រកចំណីរបស់សត្វស្លាបទឹកធំៗមួយចំនួន ដែលបានបែកខ្ញែកពីតំបន់ពងកូននៅបឹងទន្លេសាប រួមមានរនាលពណិ និង ត្រដក់តូច ។ តំបន់នេះបានទ្រទ្រង់ផងដែរនូវប្រភេទសត្វអន្តោប្រវេសន៍ ដូចជាចាបដូនតាវាលស្រែ ព្រមទាំងមួយចំនួនតូចនៃប្រភេទអកខ្មៅដីសើម ។

### ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ក្រៀល | Sarus Crane | *Grus antigone* | A1 |
| ខ្សឹប | Bengal Florican | *Houbaropsis bengalensis* | A1 |
| ចាបដូនតាវាលស្រែ | Manchurian Reed Warbler | *Acrocephalus tangorum* | A1 |
| ចាបពួកទ្រូងលឿង | Asian Golden Weaver | *Ploceus hypoxanthus* | A1 |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 |
| ត្រយ៉ងខ្លួន ស | Black-headed Ibis | *Threskiornis melanocephalus* | A1 |
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 |
| រនាលពណិ | Painted Stork | *Mycteria leucocephala* | A1 |
| អកខ្មៅដីសើម | Greater Spotted Eagle | *Aquila clanga* | A1 |

### ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងតំបន់ទំនាបវាលស្មៅ (សូមមើល តារាងឧបសម្ព័ន្ធ៤) ។

### ការគំរាមកំហែងលើជីវៈចំរុះ

ការប្រមាញ់គឺជាការគំរាមកំហែងមួយធ្ងន់ធ្ងរបំផុតចំពោះសត្វខ្សឹប និង សត្វស្លាបទឹកនៅក្នុងតំបន់ IBA នេះ ។ នៅក្នុងរដូវប្រាំង ពេលទឹកជំនន់បានស្រកចុះមានមនុស្សជាច្រើនបានធ្វើដំណើរមកកាន់តំបន់នេះ ដើម្បីធ្វើការនេសាទត្រី ច្រូតស្មៅកាប់អុស ធ្វើដំណាំដាំដុះផ្សេងៗនៅតាមតំបន់ដីសើម និង ឃ្វាលគោ ក្របីរាប់រយក្បាល ។ សកម្មភាពទាំងនេះបណ្តាលឱ្យមានការរំខានយ៉ាងខ្លាំងនៅក្នុងតំបន់ទាំងមូល រីឯស្រូវឡើងទឹកត្រូវបានគេធ្វើនៅប៉ែកខាងជើងនៃតំបន់នេះ ។ ការគំរាមកំហែងលើជីវៈចំរុះនៅក្នុងតំបន់នាពេលអនាគតគឺការប្រែក្លាយតំបន់វាលស្មៅទៅជាតំបន់ធ្វើស្រូវឡើងទឹក ។

### អនុសាសន៍

ការអនុវត្តន៍ច្បាប់ និង ការផ្សព្វផ្សាយចំណេះដឹងគួរតែធ្វើឡើងដោយផ្អែកលើគំរូជោគជ័យនៅក្នុងតំបន់ IBA ស្ទឹងសែន / សន្ទុក / បារ៉ាយណ៍ (KH021)។ ការងារនេះគួរផ្តោតលើការត្រួតពិនិត្យនៃការបរបាញ់ និង ការធ្វើពាណិជ្ជកម្មប្រភេទសត្វសំខាន់ៗ ពិសេសសត្វខ្សឹប និង សត្វស្លាបទឹកធំៗ ព្រមទាំងពិនិត្យមើលអត្ថប្រយោជន៍ដែលមានសក្តានុពលសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន ។

ការសិក្សាស្រាវជ្រាវគួរធ្វើឡើងបន្ថែមទៀតលើសារៈសំខាន់នៃអេកូឡូស៊ីដែលមានទំនាក់ទំនងទៅនឹងតំបន់ស្មៅលិចទឹក និង តំបន់ស្រូវឡើងទឹក ជាពិសេស ចំពោះការអភិរក្សសត្វខ្សឹប ។

ការអភិវឌ្ឍន៍កសិកម្មបន្ថែមទៀតណាមួយ ជាពិសេសការពង្រីកផ្ទៃដីស្រូវឡើងទឹកមិនគួរអនុញ្ញាតឡើយ ប្រសិនបើគ្មានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង ការស្វែងយល់នៃការជះឥទ្ធិពលលើតំបន់អេកូឡូស៊ីធម្មជាតិ ដែលសត្វខ្សឹបមានទំនាក់ទំនងជាមួយនោះទេ ។

### ឯកសារយោង

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Pech Bunnat (2002) *Field survey of eastern Tonle Sap in Siem Reap and Banteay Meanchey provinces*. Unpublished report to the Wildlife Conservation Society Cambodia Program and the BirdLife International Vietnam Program me.

Seng Kim Hout *et al.* (2002) *Field survey of seasonally flooded wetlands located in the east of Tonle Sap Lake in Kampong Thom and Siem Reap provinces.* Unpublished report to the Wildlife Conservation Society Cambodia Program and the BirdLife International Vietnam Programme.